# វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសាយ (អសកម្ម ឬការកកើតឡើងវិញ)៖ *អ្វីដែលអ្នកត្រូវដឹង*

Many Vaccine Information Statements are available in Spanish and other languages. See www.immunize.org/vis

ព័ត៌មានថ្លែងការណ៍អំពីវ៉ាក់សាំងជាច្រើន អាចរកបានជាភាសាអេស្ប៉ាញនិងភាសាដទៃទៀត។ ចូលមើល www.immunize.org/vis

## 1 ហេតុអ្វីបានជាត្រូវចាក់វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសាយ?

**វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសាយអាចបង្ការជំងឺគ្រុនផ្តាសាយ (ផ្តាសាយធំ)។**

**ជំងឺគ្រុនផ្តាសាយ**ជាជំងឺឆ្លងដែលរីកសាយភាយពេញសហរដ្ឋអាមេរិកជារៀងរាល់ឆ្នាំ ជាពិសេសចន្លោះខែតុលា និងឧសភា។ នរណាក៏អាចកើតជំងឺគ្រុនផ្តាសាយបានដែរ ប៉ុន្តែសម្រាប់មនុស្សមួយចំនួន ជំងឺនេះអាចបង្កគ្រោះថ្នាក់ខ្លាំង។ កូនង៉ែតនិងកូនក្មេង មនុស្សអាយុ 65 ឆ្នាំនិងចាស់ជាងនេះ ស្ត្រីមានផ្ទៃពោះ និងអ្នកដែលមានបញ្ហាសុខភាព ឬអ្នកដែលមានប្រព័ន្ធស៊ាំខ្សោយអាចប្រឈមនឹងហានិភ័យខ្ពស់ក្នុងការកើតជំងឺគ្រុនផ្តាសាយ។

ជំងឺរលាកសួត រោគរលាកទងសួត ដំបៅក្លាយក្នុងរន្ធឆ្អឹង និងដំបៅត្រចៀកគឺជាឧទាហរណ៍នៃជំងឺគ្រុនផ្តាសាយធ្ងន់ធ្ងរ។ ប្រសិនបើអ្នកមានបញ្ហាសុខភាពដូចជា ជំងឺបេះដូង មហារីក ឬទឹកនោមផ្អែម ជំងឺគ្រុនផ្តាសាយដែលកើតលើអ្នកអាចមានសភាពកាន់តែធ្ងន់ធ្ងរ។

ជំងឺគ្រុនផ្តាសាយអាចបង្កជាជំងឺគ្រុន គ្រុនរងា ឈឺក ឈឺសាច់ដុំ អស់កម្លាំង ក្អក ឈឺក្បាល និងហៀរសំបោរ/តឹងច្រមុះ។ អ្នកខ្លះអាចក្អួតនិងរាគ ភាគច្រើនវាកើតលើកុមារច្រើនជាងមនុស្សធំ។

ជារៀងរាល់ឆ្នាំ **មនុស្សរាប់ពាន់នាក់នៅសហរដ្ឋអាមេរិកស្លាប់ដោយសារជំងឺគ្រុនផ្តាសាយ** ហើយមនុស្សជាច្រើនចូលមន្ទីរពេទ្យដោយសារជំងឺនេះ។ វ៉ាក់សាំងជំងឺគ្រុនផ្តាសាយបង្ការជំងឺរាប់លាន និងបង្ការការទៅជួបគ្រូពេទ្យដោយជំងឺផ្តាសាយ។

## 2 វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសាយ

CDC បានណែនាំថាមនុស្សដែលមានអាយុពី 6 ខែ និងចាស់ជាងត្រូវចាក់វ៉ាក់សាំងការពារ រាល់រដូវគ្រុនផ្តាំសាយ។ **ក្មេងអាយុ 6 ខែដល់ 8 ឆ្នាំ**ត្រូវចាក់ថ្នាំ 2 ម្ជុលក្នុងមួយរដូវគ្រុនផ្តាសាយម្តងៗ។ **អ្នកផ្សេង**ត្រូវការចាក់ថ្នាំមួយម្ជុលក្នុងកំឡុងរដូវគ្រុនផ្តាសាយម្តងៗ។

បន្ទាប់ពីចាក់វ៉ាក់សាំងរួច វាត្រូវការរយៈពេល 2 សប្តាហ៍ដើម្បីបង្កើតការការពារ។

វាមានវីរុសគ្រុនផ្តាសាយជាច្រើន ហើយវីរុសទាំងនោះតែងតែផ្លាស់ប្តូរ។ ជារៀងរាល់ឆ្នាំ ថ្នាំវ៉ាក់សាំងជំងឺគ្រុនផ្តាសាយថ្មីត្រូវបានបង្កើតឡើងដើម្បីបង្ការទប់ទល់នឹងវីរុសផ្តាសាយបីទៅបួនដែលនឹងបង្កើតជាជំងឺនៅក្នុងរដូវគ្រុនផ្តាសាយខាងមុខ។ ទោះបីជាវ៉ាក់សាំងមិនត្រូវគ្នាជាមួយវីរុសទាំងស្រុងក៏ដោយ វានៅតែអាចការពារបានខ្លះ។

វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសាយ**មិនអាចបង្កឲ្យកើតជំងឺគ្រុនផ្តាសាយបានទេ។**

វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសាយនឹងត្រូវបានចាក់ក្នុងកំឡុងពេលតែមួយជាមួយវ៉ាក់សាំងដទៃទៀត។

## 3 ជជែកជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក

ប្រាប់អ្នកផ្តល់ថ្នាំវ៉ាក់សាំង ប្រសិនបើអ្នកទទួលការចាក់វ៉ាក់សាំង៖

- ធ្លាប់មាន**ប្រតិកម្មអាឡែរហ្ស៊ី**បន្ទាប់ពីចាក់ថ្នាំបង្ការជំងឺគ្រុនផ្តាសាយ ឬមានជំងឺធ្ងន់ធ្ងរ **អាឡែរហ្ស៊ីប៉ះពាល់ដល់ជីវិត។**
- ធ្លាប់មាន**ជំងឺទាក់ទងនឹងការខូចខាតប្រព័ន្ធសសៃប្រសាទខួរក្បាលម៉្យាង មានឈ្មោះថា Guillain-Barré Syndrome (GBS)**

ក្នុងករណីមួយចំនួន អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេចក្នុងការពន្យារការចាក់វ៉ាក់សាំងជំងឺគ្រុនផ្តាសាយទៅការណាត់ជួបលើកក្រោយ។

អ្នកដែលមានជំងឺបន្តិចបន្តួចដូចជា ជំងឺគ្រុនផ្តាសាយប្រហែលជាអាចទទួលការចាក់វ៉ាក់សាំងបាន។ អ្នកដែលមានជំងឺស្រាលឬធ្ងន់គួរតែរង់ចាំរហូតដលជាសះស្បើយសិន មុនពេលទទួលបានការចាក់ថ្នាំបង្ការ។

អ្នកផ្តលសេវាថែទាំសុខភាពរបស់អ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នក។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 | ហានិភ័យនៃប្រតិកម្មថ្នាំវ៉ាក់សាំង

- បឈឺក ក្រហមនិងហើមនៅត្រង់កន្លែងចាក់ថ្នាំ គ្រុនក្តៅ ឈឺសាច់ដុំ និងឈឺប ក្បាលអាចកើតឡើងក្រោយពេលចាក់វ៉ាក់សាំង។
- វាអាចមានហានិភ័យតិចតួចក្នុងការកើតជំងឺទាក់ទងនឹងការខូចខាត ប្រព័ន្ធសរសៃប្រសាទខួរក្បាលម្យ៉ាងមានឈ្មោះថា Guillain-Barré Syndrome (GBS)។

ក្មេងតូចដែលទទួលការចាក់ថ្នាំគ្រុនផ្តាសាយ រួមជាមួយវ៉ាក់សាំង pneumococcal (PCV13) និង/ឬវ៉ាក់សាំង DTaP នៅក្នុងពេលតែមួយអាចនឹងមានការប្រកាច់ដោយសារគ្រុនក្តៅ។ ប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើជាក្មេងដែលទទួលការចាក់វ៉ាក់សាំងមានជំងឺប្រកាច់។

ពេលខ្លះមនុស្សខ្សោយចង់សន្លប់ក្រោយដំណើរការវេជ្ជសាស្រ្ត រួមទាំងការចាក់វ៉ាក់សាំងផងដែរ។ ត្រូវប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកវិលមុខឬ ព្រិលភ្នែក ឬហឹងត្រចៀក។

ដូចទៅនឹងថ្នាំដទៃទៀតដែរ វាអាចមានឱកាសតិចតួចបំផុតដែលវ៉ាក់សាំងបង្កទៅជាប្រតិកម្មអាឡែរហ្សីធ្ងន់ធ្ងរ ឬរបួសធ្ងន់ធ្ងរដទៃទៀត ឬស្លាប់។

## 5 | ចុះបើសិនមានប្រតិកម្មធ្ងន់ធ្ងរ ?

ប្រតិកម្មអាឡែរហ្សីអាចកើតមានឡើង បន្ទាប់ពីអ្នកទទួលវ៉ាក់សាំងចាកចេញពីគ្លីនិក។ ប្រសិនបើអ្នកបានឃើញសញ្ញានៃប្រតិកម្មអាឡែរហ្សីធ្ងន់ធ្ងរ (កន្ទាលត្រអាក ហើមមុខនិងបំពង់ក ពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខឬខ្សោយ) ទូរស័ព្ទទៅ **9-1-1** និងនាំជន់នោះទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។

សម្រាប់រោគសញ្ញាផ្សេងទៀតដែលអ្នកមានការបារម្ភ សូមទូរស័ព្ទទៅកាន់អ្នកផ្តល់សេវាថែទាំសុខភាព។

ប្រតិកម្មត្រឡប់គួរតែត្រូវបានរាយការណ៍ទៅកាន់ប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍ថ្នាំបង្ការរោគមិនល្អ (Vaccine Adverse Event Reporting System,VAERS)។ អ្នកផ្តល់សេវាថែទាំសុខភាពនឹងធ្វើការរាយការណ៍ ឬអ្នកធ្វើវាខ្លួនឯង។ ចូលមើល VAERS ទៅកាន់គេហទំព័រ **www.vaers.hhs.gov** ឬទូរស័ព្ទទៅកាន់ **1-800-822-7967**។ *VAERS គឺជាការរាយការណ៍ប្រតិកម្មតែមួយគត់ ហើយបុគ្គលិក VAERS ក៏មិនផ្តល់ដំបូន្មានវេជ្ជសាស្រ្តដែរ។*

## 6 | កម្មវិធីជាតិសងសំណងរបួសថ្នាំបង្ការរោគ

កម្មវិធីជាតិសងសំណងរបួសថ្នាំបង្ការរោគ ( National Vaccine Injury Compensation Program, VICP ) គឺជាកម្មវិធីសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីសងសំណងឲ្យមនុស្សដែលបានទទួលរង របួសដោយថ្នាំបង្ការរោគខ្លះ។ ចូលគេហទំព័រ VICP តាមរយៈ **www.hrsa.gov/vaccinecompensation** ឬទូរស័ព្ទទៅកាន់ **1-800-338-2382** ដើម្បីស្វែងយល់អំពីកម្មវិធីនិងបំពេញការទាមទារ។ វាមានការកម្រិតពេល ដើម្បីប្តឹងបណ្តឹងសំណង សម្រាប់ប្រាក់សំណង។

## 7 | តើខ្ញុំអាចស្វែងយល់ថែមទៀតយ៉ាងដូចម្តេច ?

- សួរអ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក។
- ទូរស័ព្ទទៅក្រសួងសុខភាពតាមមូលដ្ឋាន ឬរដ្ឋ។
- ទាក់ទងមជ្ឈមណ្ឌលសំរាប់ទប់ស្កាត់ និងការពារជំងឺ (**Centers for Disease Control and Prevention, CDC**):-
  - ទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - មើលគេហទំព័ររបស់ CDC នៅ **www.cdc.gov/fslu**

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណាត្រឹមត្រូវ. ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត. ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។


DCH-0457CA
AUTH: P. H. S., Act 42, Sect. 2126.

Translation provided by the California Department of Public Health, Immunization Branch

Vaccine Information Statement (Interim)
Inactivated Influenza Vaccine

Office use only

8/15/2019 | Khmer | 42 U.S.C. § 300aa-26